# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ប្រាក់ឧបត្ថម្ភចៅក្រម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៩៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សា កំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២

### សំរេច

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ប្រាក់ឧបត្ថម្ភចៅក្រម បន្ថែមលើប្រាក់បៀវត្សមូលដ្ឋានប្រចាំខែ ជូនដល់ចៅក្រម និងព្រះរាជអាជ្ញា ដែលកំពុងបំពេញការងារ អមសាលាជំរះក្តី និង ចៅក្រមដែលកំពុងបំពេញការងារនៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ និង ស្ថាប័នរដ្ឋផ្សេងៗទៀត។

ប្រាក់ឧបត្ថម្ភចៅក្រមនេះ ត្រូវបើកផ្តល់ជូនចាប់ពី ខែ មករា ឆ្នាំ ២០០៣ ។

**មាត្រា ២.-**

ប្រាក់ឧបត្ថម្ភចៅក្រម និង ព្រះរាជអាជ្ញា ប្រចាំខែ ត្រូវកំណត់ដូចខាងក្រោមៈ

- ប្រធានតុលាការកំពូល និង អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចំនួន (ពីរលានប្រាំរយពាន់រៀល) ២ ៥០០ ០០០ រៀល

-ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ចំនួន (ពីរលានពីររយពាន់រៀល)២ ២០០ ០០០ រៀល

-អនុប្រធានសាលាឧទ្ធរណ៍អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ចំនួន (ពីរលានរៀល) ២ ០០០ ០០០រៀល

-ប្រធានតុលាការខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ចៅក្រមតុលាការកំពូល ព្រះរាជអាជ្ញាអមតុលាការកំពូល ចៅក្រមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចៅក្រមបំពេញការងារនៅលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ និងស្ថាប័នរដ្ឋផ្សេងៗទៀត ចំនួន (មួយលានប្រាំពីររយពាន់រៀល) ១ ៧០០ ០០០ រៀល

-អនុប្រធានតុលាការនិងព្រះរាជអាជ្ញារងអមតុលាការខេត្ត ក្រុងចំនួន(មួយលានប្រាំរយពាន់រៀល)១៥០០ ០០០រៀល

- ចៅក្រមតុលាការខេត្ត ក្រុង ចំនួន (មួយលានបីរយពាន់រៀល)១ ៣០០ ០០០ រៀល

- ចៅក្រម ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងកម្មសិក្សា ត្រូវទទួលបានប្រាក់ឧបត្ថម្ភចៅក្រមចំនួន(ប្រាំរយពាន់រៀល) ៥០០ ០០០រៀល

**មាត្រា ៣.-**

ចៅក្រមដែលកាន់មុខតំណែងច្រើន ត្រូវបានអនុញ្ញាតអោយជ្រើសរើសយកប្រាក់ឧបត្ថម្ភចៅក្រម តែមួយ ប៉ុណ្ណោះ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ